# ៣២- រឿង ស្រីមាយាដកខ្ចី

មានបុរសម្នាក់និងស្រីម្នាក់ ជាប្តីប្រពន្ធ នៅក្នុងស្រុកមួយ ប្តីជាមនុស្សចិត្តត្រង់ តែគ្មានប្រាជ្ញា ឯនាងប្រពន្ធនោះ ជាស្រីចិត្តមិនត្រង់នឹងប្តី តែចេះមាយាច្រើន ។

ថ្ងៃមួយនាងប្រពន្ធ មានចិត្តប្រាថ្នាចង់ជួបនឹងសហាយណាស់ ដោយឃ្លាតគ្នាយូរហើយ តែមិនដឹងជាធ្វើម្តេចនឹងទៅជួបបាន ព្រោះភូមិនោះនៅឆ្ងាយពីគ្នា បើដើរទៅខ្លាចខ្មោចលង ។ នាងប្រពន្ធក៏និយាយនឹងប្តីខ្លួនថា «អ្នក! ល្ងាចនេះយើងគិតទៅរកទិញមាន់មួយ មកធ្វើស៊ីបាយម្តង អ្នកចង់ស៊ីទេ ?» ។ ប្តីតបវិញថា «ចង់ស៊ីដែរ » ។ ប្រពន្ធថា «ខ្ញុំចង់ស៊ីខ្ចួរខ្ចី» ។ ប្តីថា « អើ! អញក៏ចង់ស៊ីខ្ចួរខ្ចីដែរ» ថាហើយ ក៏បបួលគ្នាចុះដើរទៅទិញមាន់អ្នកស្រុក នៅភូមិជិតផ្ទះសហាយនោះ ។ ប្តីនិងប្រពន្ធបបួលគ្នាសួររកទិញគ្រប់តែផ្ទះ ។ នាងប្រពន្ធដើរបែកពីប្តីទៅជួបសហាយ វានិយាយកិច្ចកលផ្សេងៗ រួចមកជួបនឹងប្តីវិញ ហើយប្រាប់ប្តីថា «អ្នក ! ផ្ទះឯណោះគេមានមាន់លក់ គេប្រាប់ខ្ញុំអម្បាញ់មិញ » ។ ប្តីព្រមទៅតាមប្រពន្ធប្រាប់ ក៏ទិញបានមេមាន់មួយ យួរត្រឡប់មកផ្ទះវិញ ពេលនោះជាពេលពន់ព្រលប់ ទៅដល់ពាក់កណ្តាលផ្លូវ ស្រាប់តែនាងប្រពន្ធធ្វើមាយាគក់ដើមទ្រូង ហើយថា «ឱ ! អ្នកអើយ ! ភ្លេចដូចគេលត់ទៅហើយ » ។ ប្តីសួរថា «ភ្លេចអី ?» ។ ប្រពន្ធថា « ភ្លេចខ្ចីទៅហើយអ្នក ! បើដូច្នោះអ្នកឯងនៅៗនេះសិនចុះ ខ្ញុំរត់ទៅវាឆាប់» ហើយនាងនោះរត់ទៅ ។ ប្តីក៏ឈរចាំប្រពន្ធ ឯនាងប្រពន្ធ កាលឃ្លាតពីប្តីហើយ ក៏គេចទៅជួបនឹងប្រុសសហាយខ្លួន ហេតុតែរឭកសហាយខ្លាំងណាស់ក៏ប្រះដេកទៅដី មិនរកផ្ទះសម្បែងទេ ដោយប្រញាប់ទៅជួបប្តីវិញ ។

ឯបុរសសហាយនោះ ក៏ទទួលភារៈនាងនោះទៅ រួចនាងនោះយកខ្ចីពីសហាយ ហើយផ្តាំថា «ល្ងាចនេះ ឲ្យអ្នកបងចាំមើល បើមានពេលស្រួល ចូលទៅដេកម្តងទៀតចុះ » និយាយកិច្ចការសព្វគ្រប់ហើយ នាងនោះក៏ត្រឡប់មកឯប្តីដើមវិញ ។ ដីដែលប្រះដេកនោះ ក៏នៅជាប់នឹងខ្នង មិនទាន់បោសនៅឡើយ ព្រោះដើរមកដោយប្រញាប់ លុះដើរមកដល់ប្តីខ្លួនហើយ ក៏សើចក្អាកក្អាយ និយាយទៅកាន់ប្តីថា « បើអ្នកឃើញអំមិញប្រហែលជាសើចដាច់ខ្យល់ស្លាប់ហើយ » ។ ប្តីសួរថា «សើចអី ? »។ ប្រពន្ធតបថា « នែ ! អ្នកមើលខ្នងខ្ញុំ បោសឲ្យបន្តិចមក៍ ! ហ្នឹងហើយខ្ញុំដកខ្ចី វារបូតដៃទាំងអស់ ខ្ញុំដួលផ្ងារទៅក្រោយបះជើងច្រោង បានជាដីប្រឡាក់ខ្នងខ្ញុំអស់» ។ ប្តីមិនដឹងក៏បោសខ្នងឲ្យប្រពន្ធទៅ រួចហើយនាំគ្នាដើរទៅផ្ទះ ធ្វើបាយនិងមាន់ស៊ី ធ្វើរួចហើយពេលងងឹតស៊ីបាយរួច ប្រពន្ធនិយាយនឹងប្តីថា «អ្នក ! ផ្លុំប៉ីទៅ ខ្ញុំនឹងស្តាប់» ប្តីក៏យកប៉ីមកផ្លុំ ។ ប្រពន្ធដេកស្តាប់ៗបន្តិចទៅ ក៏កិលមកដេកលើភ្លៅប្តី ហើយថា « ពីរោះណាស់អ្នក! អ្នកផ្លុំប៉ី ភ្នែកមើលរន្ធដែរឬទេ ? បើអ្នកមិនមើលរន្ធ ធ្វើម្តេចនឹងចាប់បើកបទឲ្យត្រូវទំនុក ? ប្តីតបថាទេ ! « មិនបាច់មើលរន្ធទេព្រោះដៃចាំស្ទាត់ ហើយចំណាំរន្ធផង » ។ ប្រពន្ធថា « បើដូច្នេះ ខ្ញុំបិទភ្នែកអ្នកទាំងពីរមើល អ្នកនៅតែផ្លុំពីរោះដូចដែលឬទេ ? ។ ប្តីតបថា « បិទចុះ ក៏នៅតែផ្លុំពីរោះដូចមុនដែរ » ។ ប្រពន្ធ យកដៃបិទភ្នែកប្តីខ្លួនទាំង ២ រួចហើយក៏កន្ទេកជើងឲ្យសហាយនោះឃើញ ។ បុរសសហាយឃើញស្រីសហាយខ្លួនបិទភ្នែកប្តីបាន ហើយកន្ទេកជើងឲ្យសញ្ញាដូច្នោះ ក៏ចូលទៅរួមសំវាសនឹងនាងនោះទៅ ។

លុះសហាយនោះថយចេញ ទើបប្រពន្ធលែងបិទភ្នែកប្តី ។ ប្តីនាងក៏មិនអាចដឹងដល់កិច្ចកលនោះឡើយ ។ ព្រោះហេតុនេះ បានជាមានពាក្យបុរាណថា « មាយាដកខ្ចី» មានទាំងទំនុកច្រៀងផងថា :

ស្រីទៅដកខ្ញី ស្រីអើយនាងស្រី ស្រីទៅដកខ្ញី ដកដួលទាំងខ្លួន ។ កាលដកលើកមុន តូចតន់លាក់ពួន ដកក្រោយសំនួន ផ្ទួញឲ្យប្ដីស្លាប់ ។ ប្ដីនាងអ្នកផ្លុំ នាងសុំធ្វើត្រាប់ បន្ទរអឺងអាប់ ចប់បទអុំទូក ។

**កុំពត់ស្រទៀ កុំប្រដៅស្រីខូច។**